ជោគជ័យ ហ្វាយនែន

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ

# របាយការណ៍ប្រចាំឆ្នាំ

# ២០២៣

ChokChey Finance Plc

www.chokchey.com.kh

# ប្រវត្តិសង្ខេបរបស់ ជោគជ័យ ហ្វាយនែន

**2017.07**
គ្រប់គ្រងដោយវិនិយោគទុនកូរ៉េ

**2016**
គ្រប់គ្រងដោយវិនិយោគទុនក្នុងស្រុក

**2023**

| ទ្រព្យសកម្មសរុប | បុគ្គលិក | សាខា |
|---|---|---|
| 55.5 លានដុល្លារ | 242 នាក់ | 11 |

**2022**
បើកសម្ពោធសាខាថ្មីចំនួន 2 គឺ:
- សាខាឈូក
- សាខាស្រីសន្ធរ

**2021**
បើកសម្ពោធសាខាថ្មីចំនួន 1 គឺ:
- សាខាត្រាំកក់

**2020**
- ដាក់ឲ្យប្រើប្រាស់នូវស្លាកសញ្ញាថ្មី
- បើកសម្ពោធសាខាថ្មីចំនួន 2 គឺ:
  – សាខាគងពិសី
  – សាខាកំពង់ត្រឡាច

**2019**
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធធនាគារស្នូលថ្មីរបស់កូរ៉េឈ្មោះថា **Apsara**

**2018**
បើកសម្ពោធសាខាថ្មីចំនួន 5 គឺ:
- សាខាទួលគោក
- សាខាតាខ្មៅ
- សាខាថ្នល់ទទឹង
- សាខាកំពង់ស្ពឺ
- សាខាជើងព្រៃ

**2017**
ត្រូវបានទិញដោយក្រុមហ៊ុនកូរ៉េចំនួន 2 គឺ
- **Hanshin E&C**
- **Plus International**

**2016**
- អាជ្ញាបណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មសរុប = 1.6 លានដុល្លារ
- ការិយាល័យសាខា= 01
- បុគ្គលិក= 24 នាក់

# របាយការណ៍ទិន្នន័យសំខាន់ៗ ឆ្នាំ 2023

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2023

**សមតុល្យផលបត្រឥណទាន**
48.7
លានដុល្លារ

**ដើមទុនចុះបញ្ជី**
5.5
លានដុល្លារ

**ប្រាក់ចំណេញសុទ្ធ**
1.08
លានដុល្លារ

**មូលនិធិផ្ទាល់សុទ្ធ**
13.8
លានដុល្លារ

**ចំនួនអតិថិជនសកម្ម**
5,361

**ផលលើមូលធន**
11.5%

**ចំនួនការិយាល័យប្រតិបត្តិការ**
11

**ផលលើទ្រព្យសកម្ម**
2.0%

# តារាងមាតិកា


## 1 ទិដ្ឋភាពទូទៅ
- ប្រវត្តិសង្ខេប ជោគជ័យ ហ្វាយនែន ..... 2
- របាយការណ៍ទិន្នន័យសំខាន់ៗ ឆ្នាំ 2023 ..... 3
- ភាគទុនិក ..... 5
- រចនាសម្ព័ន្ធស្ថាប័ន ..... 7
- គោលការណ៍ប្រតិបត្តិការគោល ..... 9

## 2 អំពីជោគជ័យ
- ចក្ខុវិស័យ និងបេសកកម្ម ..... 11
- បង្កើតវេទិកាបំផុសគំនិត ..... 13
- ការធ្វើមូលដ្ឋានីយកម្មដែលជោគជ័យ ..... 14
- បុគ្គលិក បុគ្គលិក និង បុគ្គលិក ..... 15
- សកម្មភាពចូលរួមរបស់បុគ្គលិក ..... 19
- ទំនើបកម្មទៅជាឌីជីថលក្នុងប្រតិបត្តិការការងារ ..... 24
- ជោគជ័យ ហ្វាយនែន និង Hanshin ..... 25
- វិន័យផ្លូវច្បាប់ និងសកម្មភាពសប្បុរសធម៌ ..... 28
- ក្រុមប្រឹក្សាភិបាល ..... 33
- គណៈគ្រប់គ្រង ..... 34

## 3 ទិដ្ឋភាពទូទៅនៃអាជីវកម្ម
- ដៃគូផ្តល់ទុនវិនិយោគ ..... 42
- ដៃគូអាជីវកម្ម ..... 42
- សមាជិកភាព ..... 42
- ទិន្នន័យសង្ខេប ..... 43
- ផលិតផលឥណទាន ..... 45
- សាខាប្រតិបត្តិការ ..... 46
- ភាពជោគជ័យរបស់អតិថិជន ..... 47

## 4 របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ..... 50
- របាយការណ៍របស់សវនករឯករាជ្យ ..... 55
- របាយការស្ថានភាពហិរញ្ញវត្ថុ ..... 58
- របាយការណ៍លទ្ធផលលម្អិត ..... 60
- របាយការស្តីពីការប្រែប្រួលមូលធន ..... 61
- របាយការណ៍លំហូរសាច់ប្រាក់ ..... 63

# ភាគទុនិក

## ក្រុមហ៊ុន Hanshin E&C

ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ 1950 ដោយជាក្រុមហ៊ុនសាងសង់លំនៅឋាន ហើយក៏បានបន្តទៅផ្នែកស្ថាប័ត្យកម្ម ការងារស៊ីវិល អគ្គិសនី និង ជំនួញដាំដុះផ្សេងៗ។ ក្រុមហ៊ុនក៏បានបន្តលូតលាស់ទៅជាក្រុមហ៊ុនសាងសង់ទូទៅ ដែលលេចធ្លោបំផុតមួយនៅក្នុងប្រទេសកូរ៉េ។

Hanshin E&C

**51%**

Plus International

**49%**

Hanshin E&C មានមោទនភាពមិនត្រឹមតែបានចូលរួមចំណែកទៅលើការអភិវឌ្ឍន៍នៃការសាងសង់ផ្ទះសំបែងចំនួន 28ម៉ឺនផ្ទះប៉ុណ្ណោះទេ តែថែមទាំងដើរតួយ៉ាងសំខាន់ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាតិ តាមរយៈការសាងសង់ផ្លូវហាយវេ ផ្លូវថ្នល់ទូទៅ ផ្លូវក្រោមដី ផ្លូវដែកល្បឿនលឿន និង ការងារជាច្រើនទៀត លើការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកសំរាប់រយៈពេលកន្លះសតវត្សកន្លងទៅនេះផងដែរ។ Hanshin ក៏ថែមទាំងបានជំរុញកេរ្តិ៍ឈ្មោះ និង កិត្តិយសជាតិ តាមរយៈការសាងសង់យ៉ាងសកម្មនៅក្រៅប្រទេស ដូចជា នៅក្នុងប្រទេសអារ៉ាប់ គុយវ៉េត និង ចិន ចាប់តាំងពីឆ្នាំ 1970។

ថ្មីៗនេះ Hanshin ក៏ថែមទាំងទទួលបានកេរ្តិ៍ឈ្មោះជាអន្តរជាតិ ទៅលើបច្ចេកវិទ្យា និង សមត្ថភាពសាងសង់ដែលទាន់សម័យរបស់ខ្លួនផងដែរ ដោយបានចូលរួមទៅលើជំនួញនានាដែលស្ថិតនៅក្នុងប្រទេសវៀតណាម និង បណ្តាប្រទេសអាស៊ីអាគ្នេយ៍ជាច្រើនទៀត ដូចជា ប្រទេសហ្វីលីពីន ភូមា កម្ពុជា ។ល។

### គម្រោងសាងសង់របស់ក្រុមហ៊ុន Hanshin E&C

- អាគារ Sultan
- ផ្ទះល្វែង Yanjil Hanshin
- ផ្លូវហាយវេ Mongolia Millenium
- អគារ Kuwait Religious Complex
- ស្ពាន Thinh long
- អគារ Jubail Royal Committee Housing Corporation
- អគារ Hanoi HH4 Mixed-use Complex
- ផ្លូវជាតិលេខ 2, 21, 22 និង 5 នៅក្នុងប្រទេសកម្ពុជា ។ល។

(ទីស្នាក់ការកណ្តាលស្ថិតនៅ ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ)

## ក្រុមហ៊ុន Plus International

មានមូលដ្ឋាននៅប្រទេសកូរ៉េខាងត្បូង ដែលការិយាល័យកណ្តាលនៅក្នុងទីក្រុង សេអ៊ូល។ ក្រុមហ៊ុនប្រតិបត្តិការទៅលើវិស័យអចលនទ្រព្យ ហើយត្រូវបានបង្កើតឡើងនៅថ្ងៃទី 4 ខែមេសា ឆ្នាំ2011។

### លក្ខណៈជំនួញ៖

- ដំណើរការគម្រោងអភិវឌ្ឍន៍អចលនទ្រព្យ
- សហការជាមួយហានសិនដើម្បីបង្កើតជំនួញថ្មី
- វិនិយោគ និង ធ្វើការជាមួយ M&A នៅក្នុងប្រទេស និង នៅបរទេស
- ស្វែងរក និង ដឹកនាំជំនួញនៅក្នុងប្រទេសកម្ពុជា និង វៀតណាម

# រចនាសម្ព័ន្ធស្ថាប័ន



# គោលការណ៍ប្រតិបត្តិការគោល

ការធ្វើមូលដ្ឋានីយកម្ម

ឧត្តមភាពនៃប្រតិបត្តិការ

បុគ្គលិក បុគ្គលិក និង បុគ្គលិក

ការគ្រប់គ្រងការផ្លាស់ប្តូរ

2

# អំពីជោគជ័យ


- ចក្ខុវិស័យ និងបេសកកម្ម ........ 11
- បង្កើតវេទិកាបំផុសគំនិត ........ 13
- ការធ្វើមូលដ្ឋានីយកម្មដែលជោគជ័យ ........ 14
- បុគ្គលិក បុគ្គលិក និង បុគ្គលិក ........ 15
- សកម្មភាពចូលរួមរបស់បុគ្គលិក ........ 19
- ទំនើបកម្មទៅជាឌីជីថលក្នុងប្រតិបត្តិការការងារ ........ 24
- ជោគជ័យ ហ្វាយនែន និង Hanshin ........ 25
- វិន័យផ្លូវច្បាប់ និងសកម្មភាពសប្បុរសធម៌ ........ 28
- ក្រុមប្រឹក្សាភិបាល ........ 33
- គណៈគ្រប់គ្រង ........ 34

## ចក្ខុវិស័យ

យើងខិតខំប្រឹងប្រែងដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុ លំដាប់ពិភពលោក " **វិសាលភាពលុបលើវិស័យធនាគារ** " ទាំងលើទំហំផលចំណេញ និង " **ការទទួលស្គាល់លើកិត្យានុភាព**" (ភាពជឿជាក់ ភាពងាយស្រួល និងល្បឿននៃសេវាកម្ម) និង " **ការបំពេញចិត្តដល់បុគ្គលិកគ្រប់ជាន់ថ្នាក់** "។

## បេសកកម្ម

ទទួលបាននូវភក្តីភាពយូរអង្វែងពីសំណាក់អតិថិជន គោលដៅស្ថិតក្នុងជីវភាពទាប និងមធ្យមតាមរយៈការផ្តល់កម្ចីនិងសេវាកម្មហិរញ្ញវត្ថុដើម្បីជួយលើកកម្ពស់ អាជីវកម្មប្រកបដោយនិរន្តរភាពព្រមទាំងរួមចំណែកបង្កើតនូវ " **វប្បធម៌នៃទម្លាប់ជោគជ័យ** " សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌

ជាស្ថាប័នប្រកបដោយសក្តានុពល យើងមានចក្ខុវិស័យរួមជាសកល ដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក ដោយឈរលើមូលដ្ឋាន" **ទម្លាប់នៃការបង្កើតភាពជោគជ័យ** " និងការអភិវឌ្ឍន៍សម្រាប់ " **ការផ្លាស់ប្តូរវិជ្ជមាន**"។ យើងទាំងអស់គ្នាប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នានិង សម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺគ្រួសារជោគជ័យ ហ្វាយនែន។

## ទស្សនៈវិស័យ

> **ការផ្តល់តម្លៃបុគ្គលិកជាធំ**
> ភាពស្មោះត្រង់
> ចេះទទួលយកវប្បធម៌ការងារល្អ
> ការគោរពតួនាទីរៀងៗខ្លួន
> អព្យាក្រឹត្យភាព

# បង្កើតវេទិកាបំផុសគំនិត

"

ពេលប្រឈមមុខនឹងបញ្ហា ឬ ការលំបាក ខ្ញុំមិនធ្លាប់មានអារម្មណ៍ថានៅម្នាក់ឯងនោះទេ ព្រោះគ្រប់កាលៈទេសៈ ខ្ញុំតែងតែមានក្រុមដែលមានស្មារតីជារួម និងរីករាយក្នុងការជួយជានិច្ច។

"

# ការធ្វើមូលដ្ឋានីកម្មដែលជោគជ័យ

## ការធ្វើការសម្រេចចិត្តដោយគណៈកម្មការដែលជាគណៈគ្រប់គ្រងក្នុងស្រុក

ថ្នាក់គ្រប់គ្រងក្នុងស្រុក ប្រកបដោយប្រសិទ្ធភាពដើរតួនាទីយ៉ាងសំខាន់ក្នុងរបៀបដែលសាជីវកម្មការជាសកលដំណើរការបានល្អ។ នៅ ជោគជ័យ ហ្វាយនែន មានជនជាតិកូរ៉េតែម្នាក់ប៉ុណ្ណោះ គឺលោក Ryan (Cheon Gil) Park ក្នុងតួនាទីជា អគ្គនាយកក្រុមហ៊ុន។ លោកជឿជាក់យ៉ាងមុតមាំថា អ្នកក្នុងស្រុកយល់ដឹងពីការអនុវត្តក្នុងតំបន់របស់ពួកគេ បានល្អប្រសើរជាងជនបរទេសដូចនេះអគ្គនាយកផ្តួចផ្តើមការពិភាក្សាដោយបើកចំហ និងជជែកដេញដោលគ្នាទៅវិញទៅមក ដើម្បីរកដំណោះស្រាយឱ្យកាន់តែល្អប្រសើរ តាមរយៈការចែករំលែកការយល់ដឹងរបស់ពួកយើង។

# បុគ្គលិក បុគ្គលិក និង បុគ្គលិក

## វប្បធម៌នៃការរៀនសូត្រ និងផ្តល់ឱកាស

បុគ្គលិកជាធនធានដ៏មានតម្លៃបំផុតសម្រាប់ ជោគជ័យ ហ្វាយនែន ។ ពួកយើងតែងព្យាយាមក្នុងការស្វែងរកអ្នកដែលមានសក្តានុពលខ្ពស់ និងបណ្តុះបណ្តាលពួកគេឱ្យក្លាយជាអ្នកដឹកនាំបែបសកល តាមរយៈកម្មវិធីបណ្តុះបណ្តាលទៅតាមកម្រិតរបស់បុគ្គលិកនីមួយៗ។

ជោគជ័យ តែងវិនិយោគយ៉ាងច្រើនលើការអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពបុគ្គលិកតាមរយៈកម្មវិធីបណ្តុះបណ្តាលក្នុងស្ថាប័ន និងក្រៅស្ថាប័ន ដើម្បីជួយបុគ្គលិកលើគ្រប់ជំហាននៃដំណើរការងារពួកគេ។ ជោគជ័យ ផ្តោតលើការកសាងក្រុមការងារ ដែលភាពរឹងមាំ ចម្រុះ និងមានសមត្ថភាព ដោយផ្តល់ឱកាសដំឡើងតួនាទី សម្រាប់បុគ្គលិកឆ្នើមៗ។ យើងជឿជាក់ថា ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ធនធានមនុស្សរបស់យើងអាចជួយបុគ្គលិកអភិវឌ្ឍជំនាញផ្ទាល់ខ្លួន ចំណេះដឹង និងសមត្ថភាព ហើយទាំងនេះជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍន៍ក្រុមការងារ ដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់ក្រុមហ៊ុន។

## រចនាសម្ព័ន្ធវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិករបស់យើង

បុគ្គលិក ការិយាល័យកណ្តាល




បុគ្គលិក សាខា



វគ្គចែករំលែកស្តីពី " ការផ្លាស់ប្តូរការគ្រប់គ្រងដល់បុគ្គលិក CBS និងនិស្សិតនៃមជ្ឈមណ្ឌលសិក្សាបច្ចេកទេសធនាគារ " ដោយលោកអគ្គនាយក

# ការចាប់យកនូវបរិបទថ្មីៗជាបន្តបន្ទាប់

លើសពីវគ្គបណ្តុះបណ្តាល បុគ្គលិករបស់យើងក៏មានឱកាសចូលរួមសិក្ខាសាលាជាច្រើន ពិព័រណ៍បច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុនៅប្រទេសសិង្ហបុរី ការប្រជុំ និងវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីទទួលបានចំណេះដឹងបន្ថែម និងបទពិសោធន៍ ពីដៃគូសហការ និយ័តករ និងការចាប់ឲ្យទាន់នូវនិន្នាការថ្មីៗ។

1

2

3

4

1 2 ពិព័រណ៍បច្ចេកវិទ្យាវិស័យហិរញ្ញវត្ថុនៅប្រទេសសិង្ហបុរី

3 4 ការធ្វើដំណើរទៅប្រទេសកូរ៉េ

# សកម្មភាពចូលរួមរបស់បុគ្គលិក

ការចូលរួមរបស់បុគ្គលិក ជោគជ័យ ហ្វាយនែន តែងភ្ជាប់ជាមួយពាក្យពេចន៍ដែលជាស្មារតីរួមថា "**យើងទាំងអស់គ្នា ដើម្បីគោលដៅតែមួយ**"។វិធីនេះគឺដើម្បីជម្រុញការចូលរួមរបស់បុគ្គលិកអោយមានសកម្មភាពជាក្រុម។លើសពីការសប្បាយរីករាយ ការបង្កើតសកម្មភាពជាក្រុមផ្តល់ឱ្យបុគ្គលិកគ្រប់គ្នានូវការជឿទុកចិត្ត ការសហការ ការយោគយល់ និង ការលើកទឹកចិត្ត។

សិក្ខាសាលា “ ការសហការ និងជំរុញសកម្មភាពប្រតិបត្តិការជាក្រុម ”

## កម្មវិធីចុះទស្សនៈកិច្ចតាមសាខារបស់ថ្នាក់គ្រប់គ្រង

ថ្នាក់គ្រប់គ្រង ជោគជ័យ ហ្វាយនែន កំណត់ផែនការប្រចាំខែដើម្បីចុះត្រួតពិនិត្យសកម្មភាពប្រតិបត្តិការរបស់សាខានីមួយៗ និងចែករំលែកយុទ្ធសាស្ត្រថ្មីដល់បុគ្គលិកក្នុងការបង្កើនប្រសិទ្ធភាពការងារ។ ការទស្សនៈកិច្ចតែងបញ្ចប់ដោយការទទួលទានអាហារសាមគ្គីជុំគ្នាក្នុងគោលបំណង លើកទឹកចិត្តបុគ្គលិកគ្រប់រូបសម្រាប់ការខិតខំប្រឹងប្រែងរបស់ពួកគាត់។

# កម្មវិធីទិវាវប្បធម៌ស្ត្រី

ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការរីកចម្រើនរបស់ក្រុមហ៊ុន។ ជោគជ័យ ហ្វាយនែន តែងតែយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់ពួកគេ នឹងមានការរៀបចំកម្មវិធីជប់លៀងអាហារពេលល្ងាចសម្រាប់ស្ត្រីទាំងអស់នៅក្នុងក្រុមហ៊ុនរបស់យើង។

# ការចែករំលែកបទពិសោធន៍ពីបុគ្គលិក

## លោក សៅ វីណា
អ្នកគ្រប់គ្រងផ្នែករដ្ឋបាល

ខ្ញុំបាទឈ្មោះ សៅ វីណា បច្ចុប្បន្នមានតួនាទីជាអ្នកគ្រប់គ្រងផ្នែករដ្ឋបាល នៅក្នុងនាយកដ្ឋានរដ្ឋបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី។ចាប់តាំងពីថ្ងៃចូលបម្រើការងារដំបូងរហូតមកដល់ពេលនេះគឺ មានរយៈពេលជាង 5ឆ្នាំហើយ ដែលខ្ញុំបាទបានបម្រើការងារ នៅក្នុងស្ថាប័ននេះ ដោយការខិតខំប្រឹងប្រែងខ្ញុំទទួលបានការរីកចម្រើន និងលើកទឹកចិត្តពីស្ថាប័នជាបន្តបន្ទាប់៖

- ខែឧសភា ឆ្នាំ2018 ៖ ចាប់ផ្តើមពីតួនាទីជា សន្តិសុខ
- ខែមករា ឆ្នាំ2021 ៖ ត្រូវបានដំឡើងតួនាទីជា បុគ្គលិករដ្ឋបាល
- ខែមករា ឆ្នាំ2023 ៖ ត្រូវបានដំឡើងតួនាទីជា បុគ្គលិករដ្ឋបាលជាន់ខ្ពស់
- ខែមករា ឆ្នាំ2024 ៖ ត្រូវបានដំឡើងតួនាទីជា អ្នកគ្រប់គ្រងរដ្ឋបាល

ក្នុងនាមខ្ញុំជាបុគ្គលិករបស់ក្រុមហ៊ុន ខ្ញុំបាទពិតជាមានមោទកភាពជាខ្លាំង ដែលគណៈគ្រប់គ្រង មើលឃើញពីការខិតខំប្រឹងប្រែងរបស់ខ្ញុំ និងបានផ្តល់ ឱកាសបំពេញការងារ ទទួលបានការបណ្តុះបណ្តាលលើអាជីពវិជ្ជាជីវៈ និងឲ្យខ្ញុំបានក្លាយជាផ្នែកមួយក្នុងការអភិវឌ្ឍន៍ក្រុមហ៊ុនឲ្យមានការរីកចម្រើនរហូតមក ដល់សព្វថ្ងៃនេះ។

"ផ្អែកលើបទពិសោធន៍របស់ខ្ញុំផ្ទាល់ ជោគជ័យ ហ្វាយនែន ជាក្រុមហ៊ុនមួយ ដែលតែងតែផ្តល់ឱកាសដល់បុគ្គលិកទាំងអស់ បានបង្ហាញនូវសមត្ថភាពរបស់ខ្លួនក្នុងការបំពេញកិច្ចការងារ ដើម្បីសម្រេចក្តីស្រម៉ៃក្នុងអាជីពការងារ និងគោលដៅហិរញ្ញវត្ថុបុគ្គល។ ខ្ញុំបាទសូមលើកទឹកចិត្តដល់សិស្ស និស្សិត និង អ្នកស្វែងរកការងារទាំងអស់ ហ៊ានធ្វើទើបមានឱកាស ! ចាប់ផ្តើមការងារនៅ ជោគជ័យ ហ្វាយនែន ឥឡូវនេះដើម្បីសម្រេចក្តីស្រម៉ៃរបស់អ្នកទាំងអស់គ្នា។"

# កញ្ញា សំណាង សុមាស

នាយិការង នាយកដ្ឋានផែនការឥណទាន និងជំនួយការ អគ្គនាយករង

ចាប់តាំងពីឆ្នាំ2020 នាងខ្ញុំបានផ្លាស់ប្តូរអាជីពការងារពីវិស័យអប់រំ មកចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី។ ដំបូងឡើយចំណេះដឹង និងការយល់ដឹងរបស់ខ្ញុំ អំពីលំហូរការងារក្នុងវិស័យហិរញ្ញវត្ថុ នៅមានកម្រិតទាបនៅឡើយ ប៉ុន្តែនាងខ្ញុំពិតជាអរគុណ ចំពោះឱកាសក្នុងការពង្រឹងចំណេះដឹងតាមរយៈការងារ វគ្គបណ្តុះបណ្តាលនានា ទាំងក្នុងក្រុមហ៊ុន និងការបញ្ជូនឲ្យទទួលបានការបណ្តុះបណ្តាលបន្ថែមពីខាងក្រៅ។

ក្នុងដំណើរនៃអាជីពការងារនេះ ខ្ញុំទទួលបានបទពិសោធន៍ដ៏មានតម្លៃទាក់ទង នឹងជំនាញការងារក៏ដូចជាការយល់ដឹងយ៉ាងទូលំទូលាយ អំពីប្រតិបត្តិការនៅក្នុង វិស័យហិរញ្ញវត្ថុ។ ខ្ញុំពិតជាអរគុណចំពោះការផ្តល់ឱកាសដែលជម្រុញឱ្យខ្ញុំ មានភាពរីកចម្រើន នៅក្នុងអាជីពការងារ និងមានឱកាសដំឡើងតួនាទីជាបន្តបន្ទាប់ដូចជា៖

- ខែមករា ឆ្នាំ2020 ៖ ចាប់ផ្តើមពីតួនាទីជា អ្នកបកប្រែ
- ខែតុលា ឆ្នាំ2020 ៖ ត្រូវបានដំឡើងតួនាទីជា ប្រធានផ្នែកអាជីវកម្មឌីជីថល និងអ្នកបកប្រែ
- ខែមករា ឆ្នាំ2021 ៖ ប្តូរតួនាទីជា ប្រធានផ្នែក ផែនការឥណទាន
- ខែមិថុនា ឆ្នាំ2022 ៖ ត្រូវបានដំឡើងតួនាទីជា នាយិការង នាយកដ្ឋានផែនការ និងបណ្តុះបណ្តាលឥណទាន
- ខែសីហា ឆ្នាំ2022 ៖ ប្តូរតួនាទីជា នាយិការង នាយកដ្ឋានផែនការឥណទាន និងជំនួយការ អគ្គនាយករង

“ជាចុងក្រោយនេះ ខ្ញុំសូមផ្តល់ជាមតិសម្រាប់អ្នកស្វែងរកការងារ គប្បីកំណត់អាទិភាពក្នុងការស្វែងរកក្រុមហ៊ុនដែលមានវប្បធម៌ការងារផ្តោតលើ ការបណ្តុះបណ្តាល ការគាំទ្រ និងលើកទឹកចិត្ត ព្រោះថាវប្បធម៌ការងារទាំងនេះ រួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍ផ្នែកសតិបញ្ញា និងវិជ្ជាជីវៈការងារ។ លើសពីនេះ គួរបន្តស្វែងរកឱកាសដើម្បីពង្រីកជំនាញ និងចំណេះដឹងរបស់អ្នក ដើម្បីរក្សាការប្រកួតប្រជែងនៅក្នុងទីផ្សារការងារដែលកំពុងរីកចម្រើនឥតឈប់ឈរ។”

# ទំនើបកម្មទៅជាឌីជីថលនៅក្នុងប្រតិបត្តិការការងារ

## ការទំនាក់ទំនងដែលទូលំទូលាយ

យើងប្រើ Microsoft Team សម្រាប់ទំនាក់ទំនងប្រតិបត្តិការការងារប្រចាំថ្ងៃ។ ការផ្តល់ជាមតិ និងគំនិតយោបល់គឺត្រូវបានស្វាគមន៍យ៉ាងខ្លាំង ដើម្បីទទួលបានការសម្រេចចិត្តដែលល្អប្រសើរ។

កម្មវិធីទូរស័ព្ទដៃដែលបានបង្កើតឡើងដោយ ជោគជ័យ ហ្វាយនែន ផ្ទាល់មានដូចជា កម្មវិធីមន្ត្រីឥណទាន (Operation App) ត្រូវបានប្រើប្រាស់សម្រាប់ការអនុម័តប្រាក់កម្ចី និងការគ្រប់គ្រងប្រាក់កម្ចី។ កម្មវិធីធនធានមនុស្ស (HR App) ប្រើប្រាស់សម្រាប់ការគ្រប់គ្រងវត្តមានបុគ្គលិក ការស្នើសុំច្បាប់សម្រាក ជាដើម។



# ជោគជ័យ ហ្វាយនែន និង Hanshin

## វិនិយោគក្នុងព្រះរាជាណាចក្រដែលពោរពេញទៅដោយឱកាស

ក្រុមហ៊ុន Hanshin E&C និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន កំពុងស្វែងរកឱកាសក្នុងការវិនិយោគថ្មីៗបន្ថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសេដ្ឋកិច្ចដ៏ស្វាហាប់ ទីតាំងយុទ្ធសាស្ត្រ និងកម្លាំងពលកម្មដ៏រឹងមាំ។

1

2

1 2

លោក Moon Kyu Choi បានចូលរួមក្នុងវេទិកា Maekyoung Cambodia និងចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា កាលពីខែមីនា ឆ្នាំ២០២៤

ទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង
លោក Choi Yong-Sun ប្រធានក្រុមហ៊ុន Hanshin E&C បានចូលជួបសម្តែងការគួរសម និងសំណេះសំណាលជាមួយ សម្តេច ធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា នៅខែឧសភា ឆ្នាំ២០២៤

# ជោគជ័យ ហ្វាយនែន និង Hanshin (ត)

## វិនិយោគក្នុងព្រះរាជាណាចក្រដែលពោរពេញទៅដោយឱកាស

សិក្ខាសាលា " ឱកាសនៃអាជីវកម្មដែលកំពុងរីកចម្រើន " រៀបចំឡើងនៅ និយ័តករបរធនបាលកិច្ច សម្របសម្រួលដោយ AmCham

ចូលរួមកម្មវិធីរបស់ AmCham

គណៈគ្រប់គ្រងនៃសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា ជួបសំណេះសំណាល ពិភាក្សាការងារជាមួយ និយតករបរធនកិច្ច

# វិន័យផ្លូវច្បាប់ និង សកម្មភាពសប្បុរសធម៌

ជោគជ័យ ហ្វាយនែន ប្តេជ្ញារក្សាទំនាក់ទំនងរឹងមាំ កេរ្តិ៍ឈ្មោះវិជ្ជមាន និងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍របស់យើង នៅពេលដែលយើងធ្វើការឆ្ពោះទៅរកគោលដៅរយៈពេលវែងរបស់យើងក្នុងការលើកកម្ពស់និរន្តរភាព និងជួយអតិថិជន ដៃគូអាជីវកម្ម និងសហគមន៍របស់យើងឱ្យរីកចម្រើនជាមួយគ្នា។ យើងប្តេជ្ញាចូលរួមជាមួយគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់ការអប់រំ ផ្តល់ជំនួយដល់សហគមន៍ដែលខ្វះខាត និងគាំទ្រដល់ការអភិវឌ្ឍន៍ទេពកោសល្យក្នុងតំបន់។ យើងក៏ជឿជាក់ផងដែរក្នុងការរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនៃទីផ្សាររបស់យើងដោយការលើកទឹកចិត្តឱ្យមានការចូលរួមរបស់បុគ្គលិក និងឱកាសស្ម័គ្រចិត្ត ក៏ដូចជាការធានានូវប្រតិបត្តិការប្រកបដោយនិរន្តរភាព និងមិត្តភាព។

KHMER SIGHT
FOUNDATION

## កម្មវិធីពិនិត្យភ្នែក និងផ្តល់វ៉ែនតាដោយឥតគិតថ្លៃ

ជោគជ័យ ហ្វាយនែន សហការជាមួយមូលនិធិចក្ខុខ្មែរ (Khmer Sight Foundation) និងអង្គការ Humanitarian With Love បានរៀបចំកម្មវិធីសប្បុរសធម៌ពិនិត្យភ្នែក ផ្តល់ជូនវ៉ែនតា និងពិនិត្យព្យាបាលជំងឺតាមក្បួនវេជ្ជសាស្ត្របុរាណចិនជូនដល់ប្រជាពលរដ្ឋនៅតំបន់ក្រុងអរិយក្សត្រ និងស្រុកល្វាឯម ខេត្តកណ្តាល ដោយឥតគិតថ្លៃ ដែលមានប្រជាពលរដ្ឋចូលរួមសរុបប្រមាណជាង 2000 នាក់ ។

យើងជឿជាក់ថាកម្មវិធីសប្បុរសធម៌នេះ នឹងដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ជីវភាព សុខុមាលភាពរបស់ប្រជាជនកម្ពុជា និងជួយឲ្យប្រជាពលរដ្ឋបានយល់ដឹងបន្ថែម អំពីការថែទាំសុខភាពភ្នែកដើម្បីចូលរួមកាត់បន្ថយអត្រាពិការភ្នែកនៅកម្ពុជា។

## ជោគជ័យ ហ្វាយនែន ទទួលបានវិញ្ញាបនបត្រសារពើពន្ធ ប្រភេទ " មាស " ពីអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៣

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

TCG2022060007
លេខ ១៣២៤៣

ភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២២
Phnom Penh, 16th, June 2022

**អគ្គនាយកដ្ឋានពន្ធដារ**
GENERAL DEPARTMENT OF TAXATION

**វិញ្ញាបនបត្រ**
**អនុលោមភាពសារពើពន្ធ**
(ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦)

អគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថា ៖
ឈ្មោះក្រុមហ៊ុន ៖ **ជោគជ័យ ហ្វាយនែន ភីអិលស៊ី**
លេខអត្តសញ្ញាណកម្មសារពើពន្ធ ៖ L001-901636771
ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ កាលបរិច្ឆេទធ្វើបច្ចុប្បន្នភាព ៖២៦ មេសា ២០១៦
សកម្មភាពអាជីវកម្ម ៖ សេវាមីក្រូហិរញ្ញវត្ថុ (ផ្តល់កម្ចី ទទួលបញ្ញើ និងផ្ទេរប្រាក់)
អាសយដ្ឋាន ៖ #៩-១១ ផ្លូវ វេងស្រេង សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ
ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ **មាស**
មានសុពលភាពរយៈពេល ២ ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២២ ដល់ ឆ្នាំ២០២៣។

**CERTIFICATE OF TAX COMPLIANCE**
(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :
Company's name : CHOKCHEY FINANCE PLC.
Tax Identification Number (TIN) : L001-901636771
Under : Department of large Taxpayers    Date of Information Update : 26 Apr 2016
Business activity(ies) : Microfinance services (loan, depository and money transfer)
Tax Compliance Type awarded : GOLD
Validity period of 2 years for the tax year of 2022 and 2023

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
hed to the Prime Minister
Royal Government
of the General Department of Taxation

គង់ វិបុល

1 **លោក ពៅ សំរេច**
នាយក នាយកដ្ឋានផ្នែកដោះស្រាយបំណុល

2 **លោក ធឿន សុធា**
នាយក នាយកដ្ឋានព័ត៌មានវិទ្យា

3 **លោក លឹម រតនៈ**
ប្រធាននាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន

4 **លោក គឿក ភត្រា**
នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

5 **លោក នៅ គឹមឡាយ**
ប្រធាននាយក នាយកដ្ឋានហិរញ្ញវត្ថុ និង ផែនការ

6 **លោក ដួង សត្យា**
ប្រធាននាយក នាយកដ្ឋានប្រតិបត្តិការ

7 **លោក ទិន ម៉ូសត្យា**
ប្រធាននាយក នាយកដ្ឋានអភិវឌ្ឍអាជីវកម្ម និង បច្ចេកវិទ្យា

8 **លោក Park, Cheon Gil**
អភិបាល និង អគ្គនាយក

9 **លោក ចេង ប៊ុនធឿន**
អគ្គនាយករង

10 **លោក អ៊ុន សេងទ្វើ**
ប្រធាននាយក នាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាម

11 **កញ្ញា សំណាង សុមាស**
នាយិការង នាយកដ្ឋានផែនការឥណទាន និង ជំនួយការអគ្គនាយករង

12 **លោកស្រី គឹម សុខេធិតា**
នាយិកាជាន់ខ្ពស់ នាយកដ្ឋានហិរញ្ញវត្ថុ និង រតនាភិបាល

13 **កញ្ញា ហុង ស្រីសំ**
នាយិការង នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

# គណៈគ្រប់គ្រង របស់ ជោគជ័យ ក្នុងកិច្ចប្រជុំ យុទ្ធសាស្ត្រប្រចាំខែ

# ក្រុមប្រឹក្សាភិបាល

លោក **Choi, Moon Kyu**
ប្រធានក្រុមប្រឹក្សាភិបាល

**ការអប់រំ**
- អនុបណ្ឌិត ពី Thunderbird School of Global Management រដ្ឋអារីហ្សូណា សហរដ្ឋអាមេរិច
- បានបញ្ចប់ការសិក្សាផ្នែកពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sogang ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**
- បច្ចុប្បន្នជាប្រធាននាយកប្រតិបត្តិក្រុមហ៊ុន Hanshin E&C
- ធ្វើការនៅក្រុមហ៊ុន Hyundai Merchant Marine
- ធ្វើការនៅក្រុមហ៊ុន Hyundai Motor

**ការអប់រំ**
- បានបញ្ចប់ការសិក្សា ផ្នែកពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Sogang ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**
- បច្ចុប្បន្នជា នាយក នាយកដ្ឋានហិរញ្ញវត្ថុក្រុមហ៊ុន Hanshin E&C
- ធ្វើការនៅក្រុមហ៊ុន Hyundai Marine & Fire Insurance

លោក **Kim, Jung Hoon**
អភិបាលឯកជ្ឈ

លោក **Park, Cheon Gil**
អភិបាល និង អគ្គនាយក

**ការអប់រំ**
- អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ YONSEI (2011) ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- វិញ្ញាបនប័ត្រ ផ្នែក Extension Marketing (2004) ពីសាកលវិទ្យាល័យ UC Berkeley រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិច
- បានបញ្ចប់ការសិក្សា ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Sogang (1998) ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៍ការងារ**
- អគ្គនាយក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វ្រីន សិនត្រល ប្រទេសកម្ពុជា
- នាយកគ្រប់គ្រង នៃសភាពាណិជ្ជកម្មកូរ៉េ (KOCHAM) ប្រចាំនៅកម្ពុជា
- នាយក នាយកដ្ឋានទីផ្សារនៃក្រុមហ៊ុន CJ Hello ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ



# គណៈគ្រប់គ្រង

ជោគជ័យ ហ្វាយនែន បើកឱកាសយ៉ាងទូលំទូលាយសម្រាប់មនុស្សគ្រប់គ្នាមិនកំណត់ចំពោះអ្នកដែលមកពីផ្នែកហិរញ្ញវត្ថុនោះទេ។ សមាជិកគណៈគ្រប់គ្រងក៏មកពីផ្នែកផ្សេងៗក្រៅពីផ្នែកហិរញ្ញវត្ថុ ដូចជាពាណិជ្ជកម្ម ទូរគមនាគមន៍ កម្មវិធី Software ការផលិត ការអប់រំក៏ដូចជាក្រុមហ៊ុនច្បាប់ រួមជាមួយប្រវត្តិការសិក្សាមកពីសាកលវិទ្យាល័យក្នុងស្រុក និងអន្តរជាតិ។ការរួមផ្សំគ្នានេះបង្កើតជា វប្បធម៌នៃភាពជោគជ័យ ដែលជាមូលដ្ឋានគ្រឹះរឹងមាំដើម្បីរីកចម្រើនទៅមុខ។

លោក **ចេង ប៊ុនធឿន**
អគ្គនាយករង

**ការអប់រំ**
- អនុបណ្ឌិត ផ្នែករដ្ឋបាលសាធារណៈ (2016)
- បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍសេដ្ឋកិច្ច (2007)

**បទពិសោធន៍ការងារ**
- 14 ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ អនុប្រធានផ្នែកកម្ចី ប្រធានផ្នែកគ្រប់គ្រងហានិភ័យ នាយករង ប្រតិបត្តិ នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ ប្រធាននាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម និង ប្រធាននាយកប្រតិបត្តិការ

**ការអប់រំ**
- អនុបណ្ឌិត ផ្នែកពាណិជ្ជកម្ម (2013)

**បទពិសោធន៍ការងារ**
- 15 ឆ្នាំនៅក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីដោះស្រាយបំណុល នាយកសាខាជាន់ខ្ពស់ មន្ត្រីបណ្តុះបណ្តាល និង អភិវឌ្ឍន៍ អនុប្រធានសាខាខេត្ត ប្រធានផ្នែកឥណទាន និងដោះស្រាយបំណុល ប្រធានប្រចាំតំបន់ និង នាយក នាយកដ្ឋានអាជីវកម្ម

លោក **ដួង សត្យា**
ប្រធាននាយក នាយកដ្ឋាន ប្រតិបត្តិការ

**លោក លឹម រតនៈ**
ប្រធាននាយក នាយកដ្ឋាន
គ្រប់គ្រងហានិភ័យឥណទាន

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកនីតិសាធារណៈ (2020)
- បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍជនបទ (2011)

**បទពិសោធន៍ការងារ**

- 17 ឆ្នាំនៅក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន ប្រធានក្រុមសាខា ប្រធានសាខា ប្រធានផ្នែកគ្រប់គ្រងហានិភ័យឥណទាន និង នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន

**លោក ទិន ម៉ូសត្យា**
ប្រធាននាយក នាយកដ្ឋាន
អភិវឌ្ឍអាជីវកម្ម និង បច្ចេកវិទ្យា

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងសហគ្រាស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (2011)

**បទពិសោធន៍ការងារ**

- 12 ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីគ្រប់គ្រងឥណទាន ប្រធានក្រុមអភិវឌ្ឍផលិតផល ប្រធានផ្នែកអភិវឌ្ឍផលិតផល នាយករង នាយកដ្ឋានអភិវឌ្ឍផលិតផល និង នាយក នាយកដ្ឋានអភិវឌ្ឍផលិតផល

**ការអប់រំ**

- អនុបណ្ឌិត ផ្នែកធនាគារ និង ហិរញ្ញវត្ថុ (2016)

**បទពិសោធន៍ការងារ**

- 11 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ជោគជ័យ និងអម្រឹត)
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ប្រធានសវនកម្មផ្ទៃក្នុង និង នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**លោក អ៊ុន សេងទ្រឿ**
ប្រធាននាយក នាយកដ្ឋាននីតិកម្ម
និងប្រតិបត្តិតាម

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ (2010)
- កំពុងបន្តការសិក្សាផ្នែក ACCA នៅសាលា CamEd Business School

**បទពិសោធន៍ការងារ**

- 13 ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីជាន់ខ្ពស់ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ មន្ត្រីជាន់ខ្ពស់ផ្នែករបាយការណ៍និយ័តកម្ម ប្រធានផ្នែករតនាភិបាល នាយករង នាយកដ្ឋានផែនការ និង នាយក នាយកដ្ឋានផែនការ

**លោក នៅ គឹមឡាយ**
ប្រធាននាយក នាយកដ្ឋាន
ហិរញ្ញវត្ថុ និង ផែនការ

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ (2017)
- កំពុងសិក្សា ACCA នៅសាលា CamEd Business School

**បទពិសោធន៍ការងារ**

- 08 ឆ្នាំ នៅក្នុងក្រុមហ៊ុនសវនកម្ម
- ធ្លាប់កាន់តំណែងជា មន្ត្រីហាត់ការផ្នែកសវនកម្ម និង ប្រធានផ្នែកសវនកម្ម

**លោកស្រី គឹម សុខេធិតា**
នាយិកាជាន់ខ្ពស់ នាយកដ្ឋានហិរញ្ញវត្ថុ និង រតនាភិបាល

**លោក ធឿន សុធា**
នាយក នាយកដ្ឋានព័ត៌មានវិទ្យា

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (2010)

**បទពិសោធន៍ការងារ**

- 15 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីគ្រប់គ្រងប្រព័ន្ធព័ត៌មាន ប្រធានផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន នាយក នាយកដ្ឋានព័ត៌មានវិទ្យា និង ប្រធាននាយក នាយកដ្ឋានព័ត៌មានវិទ្យា

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងអាជីវកម្ម (2014)

**បទពិសោធន៍ការងារ**

- 11 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន សវនករផ្ទៃក្នុង សវនករអតិរេឡ និង របាយការណ៍សវនកម្ម សវនករផ្ទៃក្នុងជាន់ខ្ពស់ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង ប្រធានផ្នែកសវនកម្មប្រតិបត្តិការ នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានផ្នែកគាំទ្រសាខា និង នាយករង នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន

**លោក តឿក ភត្រា**
នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**លោក ពៅ សំរេច**
នាយក នាយកដ្ឋាន ដោះស្រាយបំណុល

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងអាជីវកម្ម (2007)

**បទពិសោធន៍ការងារ**

- 16 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន សវនករផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ប្រធានផ្នែកសវនកម្មប្រចាំភូមិភាគ នាយក នាយកដ្ឋានសវនកម្ម និងនាយករង នាយកដ្ឋានប្រតិបត្តិការ

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុពីសាកលវិទ្យាល័យបៀលប្រាយ (2012)
- កំពុងបន្តថ្នាក់អនុបណ្ឌិត ផ្នែកធនាគារ និងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យអាស៊ីអឺរ៉ុប (2024)

**បទពិសោធន៍ការងារ**

- 10 ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា បេឡាធិការ ប្រធានបេឡា ប្រធានផ្នែកសាច់ប្រាក់ ប្រធានផ្នែករតនាភិបាល ប្រធានផ្នែកហិរញ្ញវត្ថុ និង នាយិការង នាយកដ្ឋានរតនាភិបាល

**លោកស្រី សេង គន្ធា**
នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ និង រតនាភិបាល

**កញ្ញា ហុង ស្រីសំ**
នាយិការង នាយកដ្ឋាន ធនធានមនុស្ស និងរដ្ឋបាល

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និង ហិរញ្ញវត្ថុ
- បរិញ្ញាបត្រភាសាអង់គ្លេសសម្រាប់អាជីវកម្ម (2015)

**បទពិសោធន៍ការងារ**

- 7 ឆ្នាំ ក្នុងការគ្រប់គ្រងធនធានមនុស្សពីវិស័យផ្សេងៗ
- ធ្លាប់កាន់តំណែងជា ជំនួយការផ្នែកឯកសារ មន្ត្រីធនធានមនុស្សជាន់ខ្ពស់ អ្នកសម្របសម្រួលធនធានមនុស្ស ប្រធានផ្នែកធនធានមនុស្ស និង នាយកស្តីទី នាយកដ្ឋានធនធានមនុស្ស

**លោក ឈូ សុខលាភ**
នាយករង នាយកដ្ឋាន
ដោះស្រាយបំណុល

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ

**បទពិសោធន៍ការងារ**

- 14 ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីទំនាក់ទំនងអតិថិជន មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

**កញ្ញា ប៉ែន ឧត្តម**
នាយិការង នាយកដ្ឋានហិរញ្ញវត្ថុ

**ការអប់រំ**

- អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ (2017)

**បទពិសោធន៍ការងារ**

- 2 ឆ្នាំ ក្នុងវិស័យអប់រំ និងជានាយករងនៅមជ្ឈមណ្ឌលចំណេះដឹងទូទៅ
- 9 ឆ្នាំ ក្នុងវិស័យធនាគារ ទទួលបន្ទុកលើការបិទបញ្ជីរប្រចាំខែ និងប្រចាំឆ្នាំ របស់បុត្រសម្ព័ន្ធក្នុងស្រុក និងគាំទ្រលើការត្រួតពិនិត្យ ទិន្នន័យឥណទានក្រៅស្រុក
- ធ្លាប់កាន់តំណែងជា ជំនួយការនាយក និង ជាប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល នៃនាយកដ្ឋានហិរញ្ញវត្ថុ និង ២ឆ្នាំ ធ្លាប់ជានាយិការងនៅមជ្ឈមណ្ឌលចំណេះដឹងទូទៅ ក្នុងវិស័យអប់រំ

**ការអប់រំ**

- អនុបណ្ឌិត ផ្នែកគ្រប់គ្រង (2014)
- បរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ (2008)

**បទពិសោធន៍ការងារ**

- 14 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីជាន់ខ្ពស់ផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ មន្ត្រីជាន់ខ្ពស់គណនេយ្យគ្រប់គ្រង និង ប្រធានផ្នែកផែនការ

**លោក សុខ សុភាព**
នាយករង នាយកដ្ឋានផែនការ

**ការអប់រំ**

- បរិញ្ញាបត្រ ផ្នែកបង្រៀនភាសាអង់គ្លេស (2017)

**បទពិសោធន៍ការងារ**

- 5 ឆ្នាំ ក្នុងវិស័យអប់រំ នៅសាលាអន្តរជាតិ
- ចាប់ផ្តើមការងារក្នុងវិស័យហិរញ្ញវត្ថុ តាំងពី ខែមករា ឆ្នាំ2020 ពីអ្នកបកប្រែ ប្រធានផ្នែកអាជីវកម្មឌីជីថល និង ប្រធានផ្នែកផែនការឥណទាន

**កញ្ញា សំណាង សុមាស**
នាយិការង នាយកដ្ឋាន ផែនការ
ឥណទាន និង ជំនួយការអគ្គនាយករង

**លោក រិន សុផារ៉ា**
នាយករង នាយកដ្ឋាន
ត្រួតពិនិត្យផលបត្រឥណទាន

**ការអប់រំ**

- អនុបណ្ឌិត ផ្នែកគ្រប់គ្រងធនធានមនុស្ស (2019)

**បទពិសោធន៍ការងារ**

- 9 ឆ្នាំ ក្នុងវិស័យអប់រំ
- 2 ឆ្នាំ ជាប្រធានផ្នែកធនធានមនុស្ស និង 2 ឆ្នាំ ជាប្រធានផ្នែកត្រួតពិនិត្យផលបត្រឥណទាន

**លោក វ៉េត ហ័ង**
នាយករង នាយកដ្ឋានប្រតិបត្តិការ

**ការអប់រំ**

- អនុបណ្ឌិត ផ្នែកពាណិជ្ជកម្ម (2019)

**បទពិសោធន៍ការងារ**

- 10 ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន នាយកសាខា និង ប្រធានផ្នែកគ្រប់គ្រងតំបន់

# 3

# ទិដ្ឋភាពទូទៅនៃអាជីវកម្ម


- ដៃគូផ្តល់ទុនវិនិយោគ ........ 42
- ដៃគូអាជីវកម្ម ........ 42
- សមាជិកភាព ........ 42
- ទិន្នន័យសង្ខេប ........ 43
- ផលិតផលឥណទាន ........ 45
- សាខាប្រតិបត្តិការ ........ 46
- ភាពជោគជ័យរបស់អតិថិជន ........ 47


## ដៃគូផ្តល់ទុនវិនិយោគ

## ដៃគូអាជីវកម្ម

## យើងមានក្តីរីករាយដែលជាសមាជិកនៃ៖

# ទិន្នន័យសង្ខេប

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

## សមតុល្យផលបត្រឥណទាន (គិតជាលានដុល្លារអាមេរិក) — ចំនួនអតិថិជន

48.7 លានដុល្លារ 5,361




## ផលលើទ្រព្យសកម្ម

2.0%




## ដើមទុនចុះបញ្ជី — មូលនិធិផ្ទាល់សុទ្ធ

5.5 លានដុល្លារ 13.8 លានដុល្លារ




(គិតជាលានដុល្លារអាមេរិក)

## ផលលើមូលធន

11.5%



# ផលិតផល ឥណទាន

**ឥណទានទូទៅ**
ទំហំកម្ចី : រហូតដល់ $30,000
រយៈពេលកម្ចី : រហូតដល់ 72 ខែ

**ឥណទានយានយន្ត**
ទំហំកម្ចី : រហូតដល់ $100,000
រយៈពេលកម្ចី : រហូតដល់ 84 ខែ

**ឥណទានកសិកម្ម**
ទំហំកម្ចី : រហូតដល់ $30,000
រយៈពេលកម្ចី : រហូតដល់ 72 ខែ

**ឥណទានអាជីវកម្ម**
ទំហំកម្ចី : រហូតដល់ $150,000
រយៈពេលកម្ចី : រហូតដល់ 120 ខែ

**ឥណទានកាតគ្រីយានយន្ត**
ទំហំកម្ចី : រហូតដល់ $30,000
រយៈពេលកម្ចី : រហូតដល់ 60 ខែ

**ឥណទានទាន់ចិត្ត**
ទំហំកម្ចី : រហូតដល់ $10,000
រយៈពេលកម្ចី : រហូតដល់ 60 ខែ

**ឥណទានអេឡិចត្រូនិច**
ទំហំកម្ចី : រហូតដល់ $1,000
រយៈពេលកម្ចី : រហូតដល់ 24 ខែ

**ឥណទានសង្គ្រោះបន្ទាន់**
ទំហំកម្ចី : រហូតដល់ $5,000
រយៈពេលកម្ចី : រហូតដល់ 24 ខែ

**ឥណទានក្រុមធានា**
ទំហំកម្ចី : រហូតដល់ 8 លានរៀល / ម្នាក់
រយៈពេលកម្ចី : រហូតដល់ 36 ខែ

# បណ្ដាញសាខាប្រតិបត្តិការ



**07** ខេត្ត / ក្រុងប្រតិបត្តិការ

**11** សាខាប្រតិបត្តិការ

**រាជធានីភ្នំពេញ**
1- ការិយាល័យកណ្ដាល
2- សាខាសែនសុខ

**ខេត្តកណ្ដាល**
3- សាខាតាខ្មៅ

**ខេត្តកំពង់ស្ពឺ**
4- សាខាថ្នល់ទទឹង
5- សាខាកំពង់ស្ពឺ
6- សាខាគងពិសី

**ខេត្តកំពង់ឆ្នាំង**
7- សាខាកំពង់ត្រឡាច

**ខេត្តកំពង់ចាម**
8- សាខាជើងព្រៃ
9- សាខាស្រីសន្ធរ

**ខេត្តតាកែវ**
10- សាខាត្រាំកក់

**ខេត្តកំពត**
11- សាខាឈូក

# ភាពជោគជ័យរបស់អតិថិជន

សូមអរគុណ ជោគជ័យ ហ្វាយនែន បានផ្តល់ប្រាក់កម្ចីដែលបានជួយយើងឱ្យទទួលបានប្រភពចំណូលកាន់តែរឹងមាំ និងកម្រិតជីវភាពកាន់តែប្រសើរឡើង។ លោកស្រី ឌឹម សុខនី មានប្រសាសន៍ថា ជាមួយនឹងដើមទុនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការលក់គ្រឿងទេស និងការពង្រីកចំការធំៗពួកយើងមានការរីកចម្រើនយ៉ាងខ្លាំង

## អ្នកស្រី ឌឹម សុខនី

អ្នកស្រី ឌឹម សុខនី អាយុ៤៧ឆ្នាំ រស់នៅភូមិខ្សោង ឃុំធីបាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ជាអ្នកលក់ដូរ និងជាម្ចាស់ចំការដូងក្រអូប។ ជាក់ស្តែងភាពជោគជ័យនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ។

បន្ទាប់ពីការគិតគូរយ៉ាងល្អិតល្អន់ និងរៀបចំផែនការគ្រួសារសម្រាប់ការពង្រីកអាជីវកម្មលោកស្រី និងស្វាមីបានសម្រេចចិត្តបោះជំហានជាបន្តបន្ទាប់។ ពួកគាត់បានជ្រើសរើសដៃគូហិរញ្ញវត្ថុដ៏រឹងមាំមួយគឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ដើម្បីគាំទ្រពួកគាត់ក្នុងដំណើរនេះ។

ដោយការប្រើប្រាក់កម្ចី ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ដើម្បីពង្រីកហាងលក់គ្រឿងទេស និងចំការ លោកស្រី និងស្វាមីអាចបង្កើតប្រាក់ចំណូលបន្ថែមពីអាជីវកម្មទាំងពីរ។ ទាំងនេះបានអនុញ្ញាតឱ្យពួកគេបង្កើនស្តុកសម្រាប់លក់ និងពង្រីកការដាំដុះដោយការទិញដីប្រមាណ ២ហិកតា។

រីករាយជាមួយនឹងលទ្ធផលនេះ លោកស្រី ឌឹម សុខនី បានថ្លែងអំណរគុណ ចំពោះគ្រឹះស្ថានដែលបានផ្តល់កម្ចីដែលអាចឱ្យលោកស្រីពង្រីកអាជីវកម្ម និងលើកកម្ពស់ជីវភាពគ្រួសារ។ ដោយសារការជោគជ័យនេះ បានជំរុញចិត្តលោកស្រី មានក្តីសុបិនចង់ចិញ្ចឹមមាន់ទា និងគោនៅកសិដ្ឋានមួយនាពេលអនាគត។

អ្នកស្រី ផែង ឧស្សាហ៍ មានប្រសាសន៍ថា "ខ្ញុំពេញចិត្តនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ដំណើរការផ្តល់ប្រាក់កម្ចីមានប្រសិទ្ធភាព ហើយអត្រាការប្រាក់ គឺជាអត្រាដែលអាចទទួលយកបាន ដែលអនុញ្ញាតឱ្យខ្ញុំប្រើប្រាស់ប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្ម និងទទួលបានរីកចម្រើនពិតប្រាកដ"។

## អ្នកស្រី ផែង ឧស្សាហ៍

អ្នកស្រី ផែង ឧស្សាហ៍ រស់នៅ ភូមិអូរស្វាយលិច ឃុំព្រែកគុយ ស្រុកកងមាស ខេត្តកំពង់ចាម។ ជាអ្នកដែលជឿជាក់លើ សេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន។ ក្នុងនាមជាអតិថិជនដែលពេញចិត្តលើគ្រឹះស្ថាន អ្នកស្រីទើបតែទទួលបានប្រាក់កម្ចី ដើម្បីជួយពង្រីកអាជីវកម្មលក់គ្រឿងទេស និងគ្រាប់ឈូក។

ដោយសារការជឿទុកចិត្តលើគ្រឹះស្ថាន អ្នកស្រី ផែង ឧស្សាហ៍ បានប្រើប្រាស់ប្រាក់កម្ចីដើម្បីសម្រេចបាននូវគោលដៅចំនួនពីរគឺ៖ ស្តុកគ្រឿងទេសកាន់តែច្រើននៅក្នុងហាងរបស់គាត់ និងកែលម្អគេហដ្ឋានឲ្យធំជាងមុន ដើម្បីងាយស្រួលក្នុងការស្តុកទុកគ្រាប់ឈូកឆៅបន្ថែមទៀត ដែលវាជាមុខរបរស្នូលប្រចាំថ្ងៃរបស់គាត់។

ការកើនឡើងប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកស្រី គឺជាសញ្ញាច្បាស់លាស់នៃភាពជោគជ័យរបស់អ្នកស្រីក្នុងការគ្រប់គ្រងប្រាក់កម្ចី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់កំណើនអាជីវកម្មរបស់អ្នកស្រី។

4

# របាយការណ៍ហិរញ្ញវត្ថុ


- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ..... 50
- របាយការណ៍របស់សវនករឯករាជ្យ ..... 55
- របាយការស្ថានភាពហិរញ្ញវត្ថុ ..... 58
- របាយការណ៍លទ្ធផលលម្អិត ..... 60
- របាយការស្ដីពីការប្រែប្រួលមូលធន ..... 61
- របាយការណ៍លំហូរសាច់ប្រាក់ ..... 63


# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្ដីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (ក្រុមហ៊ុន) ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្ដល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពដល់សហគ្រិនធុនតូច និងមធ្យម និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| ប្រាក់ចំណេញមុនដកពន្ធ | 1,383,882 | 5,687,755 | 1,758,717 | 7,187,877 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (301,253) | (1,238,150) | (395,507) | (1,616,437) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **1,082,629** | **4,449,605** | **1,363,210** | **5,571,440** |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាល ក៏ពុំបានផ្តល់ជាអនុសាសន៍ ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទ នេះទេ។

## ដើមទុន

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 មានចំនួន 5,500,000 ដុល្លារអាមេរិក (2022៖ 5,500,000 ដុល្លារអាមេរិក) ដែលក្នុងនោះមួយភាគហ៊ុន មានតម្លៃស្មើនឹង 10 ដុល្លារអាមេរិក។ ភាគហ៊ុន និងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន លម្អិតត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ 11។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និង សំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការ ទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោល ឥណទានអាក្រក់ ឬ ចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែល មានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចបម្រើបាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់ តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឱ្យប៉ះពាល់ដល់ វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និង បំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនដែលកើតមានឡើង ដោយសារការដាក់បញ្ចាំសម្រាប់ការធានា ចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតា របស់ក្រុមហ៊ុន។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬ អាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែល នឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបាន បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្ត ដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើង ក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយ នៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

- **លោក Moon Kyu Choi**
  ប្រធានក្រុមប្រឹក្សាភិបាល
- **លោក Cheon Gil Park**
  អភិបាល និងនាយកប្រតិបត្តិ
- **លោក Jung Hoon Kim**
  អភិបាលឯករាជ្យ

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានអភិបាលណាម្នាក់ មានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការិយបរិច្ឆេទនេះឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាភាគីម្ខាងដែលគោលបំណង ជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃមួយទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ នៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃលាភការដែលបានទទួល ឬកំណត់ នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជា សមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជា សារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវ គោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំង អនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMEs ឬ ប្រសិនបើមានការប្រាសចាកពីនេះ ដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់ចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(ឃ)វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃ ស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬ គ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើ ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី 10 ដល់ 52 ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។*

លោក Cheon Gil Park
អភិបាល និងនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 24 ខែមេសា ឆ្នាំ2024

# របាយការណ៍របស់សវនករឯករាជ្យ

### ជូនចំពោះភាគទុនិក
### ជោគជ័យ ហ្វាយនែន ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ របស់ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ហៅកាត់ ("ក្រុមហ៊ុន") ដែលរួម មានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមាន គោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី 10 ដល់ 52។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31ខែធ្នូឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀត នៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ស្របតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវ ក្រមសីលធម៌ផ្សេងៗស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ1ដល់ទី5ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន រំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំ ក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយហើយយើងខ្ញុំក៏មិនបានផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើង ខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មាន ផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការ យល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើការមានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRS for SMEs ហើយ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមាន ភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែល ទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុស ជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។អំណះអំណាងសមហេតុផល គឺជាអំណះអំណាងបានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្ត អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈនិងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិ សវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើង ដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹង អំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវ នីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណង ដើម្បីបញ្ចេញមតិលើប្រសិទ្ធភាព

នៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

- ការវាយតម្លៃ លើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋាន លើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថា តើភាពមិនច្បាស់លាស់ ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្ត លើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្តយើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មាន មានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិ សវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្ម ដែលប្រមូលបានត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឱ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថា តើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញ របាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មាន ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្ម រួមមានជាអាទិ៍វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្ត រួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត

**ឈុន ម៉ារ៉ា**
*នាយកសវនករ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 24 ខែមេសា ឆ្នាំ2024

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | 9,622 | 39,306 | 86,007 | 354,091 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 280,176 | 1,144,519 | 277,675 | 1,143,188 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | 5,772,566 | 23,580,932 | 2,288,442 | 9,421,516 |
| ឥណទានផ្តល់ដល់អតិថិជន | 48,691,592 | 198,905,153 | 52,022,303 | 214,175,821 |
| ទ្រព្យសកម្មផ្សេងៗ | 204,184 | 834,092 | 168,331 | 693,019 |
| ទ្រព្យ និងបរិក្ខារ | 375,247 | 1,532,884 | 433,087 | 1,783,019 |
| ទ្រព្យសកម្មអរូបី | 162,926 | 665,553 | 189,851 | 781,617 |
| **ទ្រព្យសកម្មសរុប** | **55,496,313** | **226,702,439** | **55,465,696** | **228,352,271** |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| បំណុលផ្សេងៗ | 621,136 | 2,537,342 | 668,934 | 2,754,002 |
| ប្រាក់កម្ចីរយៈពេលខ្លី | 23,653,782 | 96,625,699 | 24,616,420 | 101,345,801 |
| ប្រាក់កម្ចីរយៈពេលវែង | 21,511,016 | 87,872,500 | 21,487,612 | 88,464,499 |
| ពន្ធពន្យារជាបំណុល-សុទ្ធ | 237,785 | 971,352 | 29,586 | 121,806 |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 20,415 | 83,395 | 293,594 | 1,208,726 |
| **បំណុលសរុប** | **46,044,134** | **188,090,288** | **47,096,146** | **193,894,834** |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **មូលធន** | | | | |
| ដើមទុន | 5,500,000 | 22,199,000 | 5,500,000 | 22,199,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 1,713,535 | 6,999,788 | 767,320 | 3,147,611 |
| ប្រាក់ចំណេញរក្សាទុក | 2,238,644 | 9,155,370 | 2,102,230 | 8,557,942 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 257,993 | - | 552,884 |
| **មូលធនសរុប** | 9,452,179 | 38,612,151 | 8,369,550 | 34,457,437 |
| **បំណុល និងមូលធនសរុប** | **55,496,313** | **226,702,439** | **55,465,696** | **228,352,271** |

# របាយការណ៍លទ្ធផលលម្អិត

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| ចំណូលពីការប្រាក់ | 8,034,548 | 33,021,992 | 7,777,724 | 31,787,558 |
| ចំណាយលើការប្រាក់ | (2,946,754) | (12,111,159) | (2,278,947) | (9,314,056) |
| **ចំណូលលើការប្រាក់សរុប** | **5,087,794** | **20,910,833** | **5,498,777** | **22,473,502** |
| ចំណូលប្រតិបត្តិការផ្សេងៗ | 144,882 | 595,465 | 135,735 | 554,749 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | (3,477,838) | (14,293,914) | (3,652,631) | (14,928,303) |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | (370,956) | (1,524,629) | (223,164) | (912,071) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **1,383,882** | **5,687,755** | **1,758,717** | **7,187,877** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (301,253) | (1,238,150) | (395,507) | (1,616,437) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **1,082,629** | **4,449,605** | **1,363,210** | **5,571,440** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (294,891) | - | 342,166 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | **1,082,629** | **4,154,714** | **1,363,210** | **5,913,606** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2022 | 5,500,000 | 22,199,000 | 487,464 | 1,974,481 | 1,018,876 | 4,159,632 | - | 210,718 | 7,006,340 | 28,543,831 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 1,363,210 | 5,571,440 | - | - | 1,363,210 | 5,571,440 |
| ការផ្ទេរ | - | - | 279,856 | 1,173,130 | (279,856) | (1,173,130) | - | - | - | - |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 342,166 | - | 342,166 |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | 279,856 | 1,173,130 | 1,083,354 | 4,398,310 | - | 342,166 | 1,363,210 | 5,913,606 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | **5,500,000** | **22,199,000** | **767,320** | **3,147,611** | **2,102,230** | **8,557,942** | **-** | **552,884** | **8,369,550** | **34,457,437** |
| | | | | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 5,500,000 | 22,199,000 | 767,320 | 3,147,611 | 2,102,230 | 8,557,942 | - | 552,884 | 8,369,550 | 34,457,437 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 1,082,629 | 4,449,605 | - | - | 1,082,629 | 4,449,605 |
| ការផ្ទេរ | - | - | 946,215 | 3,852,177 | (946,215) | (3,852,177) | - | - | - | - |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (294,891) | - | (294,891) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | 946,215 | 3,852,177 | 136,414 | 597,428 | - | (294,891) | 1,082,629 | 4,154,714 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | **5,500,000** | **22,199,000** | **1,713,535** | **6,999,788** | **2,238,644** | **9,155,370** | **-** | **257,993** | **9,452,179** | **38,612,151** |

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **លំហូរសាច់ប្រាក់ពីសកម្មប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 1,082,629 | 4,449,605 | 1,363,210 | 5,571,440 |
| និយ័តកម្មលើ៖ | | | | |
| រំលស់ទ្រព្យ និងបរិក្ខារ | 117,757 | 483,981 | 163,577 | 668,539 |
| រំលស់ទ្រព្យសកម្មអរូបី | 26,925 | 110,662 | 26,994 | 110,324 |
| ទ្រព្យ និងបរិក្ខារដែលលុបចោល | - | - | 83 | 339 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | (500) | (2,055) | - | - |
| ការខាតបង់លើឱនភាព នៃឥណទានផ្តល់ដល់ អតិថិជន | 370,956 | 1,524,629 | 223,164 | 912,071 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 301,253 | 1,238,150 | 395,507 | 1,616,437 |
| | 1,899,020 | 7,804,972 | 2,172,535 | 8,879,150 |
| បម្រែបម្រួលនៃ៖ | | | | |
| ឥណទានផ្តល់ដល់អតិថិជន | 2,959,755 | 12,164,593 | (9,167,041) | (37,465,697) |
| ទ្រព្យសកម្មផ្សេងៗ | (35,853) | (147,356) | 11,471 | 46,882 |
| បំណុលផ្សេងៗ | (47,798) | (196,450) | 183,444 | 749,736 |
| **សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ** | **4,775,124** | **19,625,759** | **(6,799,591)** | **(27,789,929)** |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (366,233) | (1,505,218) | (279,061) | (1,140,522) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | **4,408,891** | **18,120,541** | **(7,078,652)** | **(28,930,451)** |

| | 2023 | | 2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (59,917) | (246,259) | (177,118) | (723,881) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | 500 | 2,055 | - | - |
| គណនីបញ្ញើមានកាលកំណត់នៅធនាគារ | (2,000,000) | (8,220,000) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(2,059,417)** | **(8,464,204)** | **(177,118)** | **(723,881)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | - | - | 8,858,071 | 36,202,936 |
| ការទូទាត់សងប្រាក់កម្ចី | (939,234) | (3,860,252) | - | - |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | **(939,234)** | **(3,860,252)** | **8,858,071** | **36,202,936** |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 1,410,240 | 5,796,085 | 1,602,301 | 6,548,604 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា | 2,377,124 | 9,786,620 | 774,823 | 3,156,629 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (111,323) | - | 81,387 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ (កំណត់សម្គាល់ 19)** | **3,787,364** | **15,471,382** | **2,377,124** | **9,786,620** |

# ជោគជ័យ ហ្វាយនែន ភីអិលស៊ី

ផ្ទះលេខ 9-11 ផ្លូវវេងស្រេង, ភូមិដំណាក់ធំ 5
សង្កាត់ស្ទឹងមានជ័យទី 3 ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ : 023 922 126
អ៊ីម៉ែល : info@chokchey.com.kh
គេហទំព័រ : www.chokchey.com.kh